# ការពិនិត្យជាសកលតាមកាលកំណត់សម្រាប់ប្រទេសកម្ពុជា

## ដំណាក់កាលនៃការអនុវត្ត

- ដំណើរការពិនិត្យជាសកលតាមកាលកំណត់ (UPR) គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិដែលពិនិត្យលើការប្រតិបត្តិរបស់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិនីមួយៗ ចំពោះកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋនីមួយៗ។
- ក្នុងអំឡុងពេល UPR រដ្ឋជាសមាជិកអង្គការសហប្រជាជាតិផ្តល់អនុសាសន៍នានាទៅដល់រដ្ឋត្រូវទទួលការពិនិត្យដែលអាចធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សបានល្អប្រសើរឡើង។




### ដំណើរការពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទី៣ របស់ប្រទេសកម្ពុជា

លទ្ធផលនៃការពិនិត្យជាសកលតាមកាលកំណត់ជុំទី៣ នៃប្រទេសកម្ពុជា ឆ្នាំ២០១៩៖

- ក្នុងខែមករា ឆ្នាំ២០១៩ **ប្រទេសកម្ពុជាបានទទួលអនុសាសន៍សរុបចំនួន១៩៨** ពីរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន៧៣ ទាក់ទងនឹងបញ្ហាផ្នែកសិទ្ធិមនុស្សផ្សេងៗ។
- ក្នុងខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានទទួលយក**អនុសាសន៍ចំនួន ១៧៣**។

  - ទាក់ទងនឹងបញ្ហាផ្នែកសិទ្ធិមនុស្សផ្សេងៗជាច្រើន ដូចជា សិទ្ធិដីធ្លី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការការពារដល់អ្នកការពារសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី និងសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (សូជី) ជាដើម។

- រាជរដ្ឋាភិបាលកម្ពុជាបានកត់សម្គាល់**អនុសាសន៍ចំនួន ២៥**

  - ទាក់ទងនឹងសេរីភាពមូលដ្ឋាន សេរីភាពព័ត៌មាននិង ការដោះលែងអ្នកទោសនយោបាយ។

ផលិតដោយ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CIVICUS

ឧបត្ថម្ភដោយ

Activity supported by the Canada Fund for Local Initiatives
Activité réalisée avec l'appui du Fonds canadien d'initiatives locales
Canada

បោះពុម្ពឡើងវិញដោយ

SUOMI FINLAND
Embassy of Finland Bangkok

# ដំណាក់កាលបន្ទាប់ ៖ ការអនុវត្តអនុសាសន៍

➡ ការអនុវត្តអនុសាសន៍គឺជាគោលបំណងចុងក្រោយនៃដំណើរការ UPR ដើម្បីឱ្យមានការគោរពសិទ្ធិមនុស្សល្អប្រសើរនៅកម្ពុជា

## តួនាទីរបស់ដៃគូផ្សេងៗក្នុងដំណាក់កាលអនុវត្ត



### រាជរដ្ឋាភិបាលកម្ពុជា



- ✓ តាក់តែងគោលនយោបាយ។
- ✓ បង្កើតច្បាប់។
- ✓ ប្រឹក្សាយោបល់ និងសហការជាមួយសង្គមស៊ីវិល។
  - ➡ ប្រឹក្សាយោបល់ដោយបរិយាប័ន្ន ប្រកបដោយអត្ថន័យនិងជាទៀងទាត់ ដើម្បីធ្វើបច្ចុប្បន្នអំពីវឌ្ឍនៈភាព និងស្វែងរកការពិគ្រោះយោបល់លើបញ្ហាជាក់លាក់។
- ✓ បង្កើតយន្តការថ្នាក់ជាតិដើម្បីរាយការណ៍ និងតាមដាន
  - ➡ សម្របសម្រួលនិងប្រឹក្សាយោបល់ជាអចិន្ត្រៃយ៍នៅគ្រប់ក្រសួងនិងជាមួយដៃគូពាក់ព័ន្ធទាំងអស់ (សង្គមស៊ីវិល ភ្នាក់ងារអង្គការសហប្រជាជាតិ សភា និងតុលាការ)។
- ✓ បង្កើតផែនការសកម្មភាពផ្នែកសិទ្ធិមនុស្សដើម្បីកំណត់ក្រសួងដែលទទួលខុសត្រូវចំពោះការអនុវត្ត និងបង្កើតសូចនាករដើម្បីវាស់វែងលើការអនុវត្ត។

### ប្រជាពលរដ្ឋកម្ពុជាទូទៅ

- ✓ អាចចូលរួមកិច្ចសន្ទនាជាសាធារណៈជុំវិញដំណើរការ UPR អនុសាសន៍ និងបញ្ហាសិទ្ធិមនុស្ស ដែលទាក់ទងនឹងអនុសាសន៍ទាំងនោះ។
- ✓ អាចជួយតាមដានលើការអនុវត្តអនុសាសន៍។
- ✓ លើកទឹកចិត្តដល់សាធារណជនក្នុងការជំរុញឱ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ដែលបានទទួលយកទាំងនោះ។



### សង្គមស៊ីវិល

= អង្គការសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស សហជីព អង្គការនៅមូលដ្ឋាន។

- ✓ អាចជួយនិងសហការជាមួយដៃគូពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមនិងគាំទ្រអនុវត្តអនុសាសន៍។
  - ➡ ផ្តល់យោបល់ដល់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សជាក់លាក់។
  - ➡ តស៊ូមតិអំពីបញ្ហាសិទ្ធិមនុស្សដែលផ្អែកលើអនុសាសន៍។
- ✓ អាចឃ្លាំមើល និងរាយការណ៍អំពីការអនុវត្តអនុសាសន៍។

### រដ្ឋដែលផ្តល់អនុសាសន៍



រដ្ឋជាសមាជិកអង្គការសហប្រជាជាតិដែលផ្តល់អនុសាសន៍

- ✓ បន្តកិច្ចសន្ទនាទ្វេរភាគីជាមួយរដ្ឋាភិបាល។
  - ➡ ស្នើសុំព័ត៌មានលម្អិតបន្ថែមទាក់ទងនឹងផែនការអនុវត្តដែលនេះក៏អាចផ្តល់ជំនួយបច្ចេកទេសផងដែរ។
  - ➡ អនុសាសន៍នានាអាចបង្កើតជាមូលដ្ឋាននៃការពិភាក្សារវាងរដ្ឋដែលផ្តល់អនុសាសន៍និងរដ្ឋដែលត្រូវទទួលការពិនិត្យដូចជាក្នុងពេលកិច្ចសន្ទនាសិទ្ធិមនុស្សទ្វេរភាគីជាដើម។
- ✓ គាំទ្រសង្គមស៊ីវិលនៅកម្ពុជា។
  - ➡ ផ្នែកហិរញ្ញវត្ថុ (គាំទ្រសង្គមស៊ីវិលធ្វើយុទ្ធនាការតស៊ូមតិ និងតាមដានការអនុវត្តអនុសាសន៍)។
  - ➡ ចូលរួមដល់កិច្ចការពារលំហសង្គមស៊ីវិលដើម្បីធានាថាអង្គការសង្គមស៊ីវិលមានសេរីភាពក្នុងការអនុវត្តសកម្មភាពការងារទាក់ទងនឹង UPR ដោយជួយការពារអង្គការសង្គមស៊ីវិលទាំងនោះពីផលវិបាកនានាដែលកើតឡើងដោយសារការងាររបស់ពួកគេ។
- ✓ តាមដាន និងរាយការណ៍ អំពីការអនុវត្តអនុសាសន៍។

សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការពិនិត្យជាសកលតាមកាលកំណត់របស់ប្រទេសកម្ពុជានៅជុំទី៣ សូមចូលទៅកាន់គេហទំព័រ sithi.org/upr

@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org

CC BY NC SA

ខែ ឧសភា ឆ្នាំ២០២៣